# ចេញពីការពឹងផ្អែកលើជំនួយឆ្ពោះទៅកាន់វិបុលភាពរួម: ការគ្រប់គ្រងធនធានប្រេងកាតនិងឧស្ម័នរបស់កម្ពុជា*

*អត្ថបទនេះ រួមបញ្ចូលនូវបទបង្ហាញស្តីពីការគ្រប់គ្រងធនធានប្រេងកាតនិងឧស្ម័នរបស់កម្ពុជា ដោយលោក **Douglas Gardner** អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និង ឯ.ឧ. **Joseph Mussomeli** អគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជានៅសន្និសីទចក្ខុវិស័យកម្ពុជា នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧ ព្រមទាំងមានការបូកសរុបជាទូទៅដោយលោកបណ្ឌិត សុខ ស៊ីណា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន **CDRI** ។*

## ការបូកសរុបទូទៅដោយវិទ្យាស្ថាន CDRI

យោងតាមអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) ប្រទេសកម្ពុជាមានតំបន់ប្រេងកាតនៅបាតសមុទ្រ ៦កន្លែង (តំបន់ A, B, C, D និង F) និងតំបន់សម្បទានត្រួតគ្នាជាមួយថៃ (OCA) មួយកន្លែង ។ តំបន់ជុំវិញបឹងទន្លេសាបក៏អាចមានប្រេងកាតនិងឧស្ម័ន (O&G) ដែរ ហើយសព្វថ្ងៃកំពុងធ្វើការស្រាវជ្រាវ ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងធនាគារពិភពលោក (WB) ប៉ាន់ស្មានថា ចំណូលប្រចាំឆ្នាំពី O&G អាចមានរហូតដល់ ២ពាន់លានដុល្លារ រីឯរដ្ឋាភិបាលកម្ពុជាបានព្យាករណ៍ទាបជាខ្លាំងត្រឹម ១០០-៣០០លានដុល្លារ ប៉ុណ្ណោះ ។ ទោះបីតួលេខប៉ាន់ស្មានវាខុសគ្នាក្តី ប៉ុន្តែមានការយល់ស្របជាទូទៅថា ចំណូលពីការនាំចេញ O&G អាចកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាលើជំនួយអភិវឌ្ឍន៍បរទេស និងជួយជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ច ។

មានបទពិសោធន៍ជាក់ស្តែងជាច្រើនបង្ហាញថា ប្រទេសសំបូរធនធានខ្លះនៅតែមិនរីកចំរើន ទោះបីជាបានទទួលចំណូលសន្ធឹកសន្ធាប់ពីការនាំចេញធនធានធម្មជាតិក៏ដោយ ។ សេដ្ឋវិទូនានា បានធ្វើការពិពណ៌នាបាតុភូតនេះថាជា "បណ្តាសាធនធាន" ដោយសំដៅដល់ការលូតលាស់ និងអភិវឌ្ឍន៍អវិជ្ជមានដែលពាក់ព័ន្ធនឹងសម្បត្តិធម្មជាតិ ។ បណ្តាសាធនធានមានមូលហេតុច្រើនយ៉ាង ដូចជា "ជំងឺហូឡង់" រឺការថយចុះនៅក្នុងវិស័យនាំចេញមិនមែនប្រេងកាតជាដើម ។ មូលផលផ្សេងទៀត អាចជាការខ្ជះខ្ជាយ អំពើពុករលួយដែលនាំឱ្យថយចុះវិនិយោគ ហើយនៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនអាចកើតមានទំនាស់ហិង្សាទៀតផង ។ រីឯ "ពរធនធាន" សំដៅដល់ទំនាក់ទំនងវិជ្ជមានរវាងកំណើន/អភិវឌ្ឍន៍ ហើយនិងសម្បត្តិធម្មជាតិ ។ ប្រទេសដែលអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបានល្អ ទាន់ពេលវេលា និងចេះប្រើប្រាស់ចំណូលពីប្រេងកាតដោយឈ្លាសវៃ អាចជំនះលើហានិភ័យនៃបណ្តាសាធនធានបាន ។

ឥទ្ធិពលអវិជ្ជមានខ្លះអាចកើតមាននៅពេលយកចំណូល O&G មកប្រើដោយគ្មានផែនការ និងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន ។ ទំនិញប្រើប្រាស់ជាទូទៅអាចឡើងថ្លៃ ហើយប្រាក់រៀលអាចឡើងថ្លៃដែរ ដែលធ្វើឱ្យចុះខ្សោយដល់សមត្ថភាពប្រកួតប្រជែងនៃទំនិញនាំចេញជាកសិផលសំរាប់លក់យកប្រាក់ និងផលិតផលពីវិស័យកាត់ដេរ ។ ការថយចុះទំនិញនាំចេញទាំងនេះ អាចនាំឱ្យមនុស្សជាច្រើនអស់ការងារធ្វើ ហើយបង្កផលវិបាកធ្ងន់ធ្ងរដល់សេដ្ឋកិច្ចទាំងមូល ។

សកម្មភាព និងការីតថ្លៃក្នុងវិស័យមិនមែនពាណិជ្ជកម្ម ដូចជាវិស័យសំណង់ និងសេវាកម្ម ក៏ប្រហែលកើនឡើងដែរ ដោយសារមានតំរូវការខ្ពស់និងអំណាចទិញខ្លាំងពីវិស័យ O&G ។ អាគារ ផ្ទះ ដី នឹងឡើងថ្លៃទាំងអស់ប្រសិនតំរូវការរបស់ទាំងនេះ កើនឡើងដោយសារកំលាំងប្រាក់ចំណូលពីប្រេងកាត ហើយកម្ពុជាអាចក្លាយជាប្រទេសត្រូវចំណាយអស់ច្រើនជាងគេក្នុងការរស់នៅ និងវិនិយោគ ។

ថ្វីបើចំណូលពី O&G នាំឱ្យមានហានិភ័យច្រើន ប៉ុន្តែវាក៏ផ្តល់ឱកាសពិសេសបំផុតសំរាប់ឱ្យរដ្ឋាភិបាល ប្រើប្រាស់ធនធានទាំងនេះដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយធ្វើវិនិយោគទៅលើផ្លូវជាតិ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការអប់រំ សុខាភិបាល ផ្លូវជនបទ ប្រព័ន្ធស្រោចស្រព និងសេវាផ្សេងៗ ។ ការវិនិយោគទៅលើសម្បត្តិសាធារណៈទាំងនេះ នឹងនាំឱ្យមានកំណើនក្នុងរយៈពេលខ្លី និងវែង ។ ចំណូលពីប្រេងកាត ក៏អាចយកមកប្រើប្រាស់ដើម្បីពង្រឹងសំណាញ់សុវត្ថិភាពសង្គម ដោយបង្កើតមូលនិធិសង្គម និងមូលនិធិសោធននិវត្តន៍ ។ ការវិនិយោគទាំងនេះ អាចផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនកម្ពុជា ដូច្នេះវានឹងជួយសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា (CMDGs) ។

ចំណូលពីប្រេងកាត ក៏ផ្តល់ឱកាសល្អមួយដែរសំរាប់ឱ្យរដ្ឋាភិបាលពន្លឿនកំណែទំរង់ក្នុងវិស័យសាធារណៈ ដោយបង្កើនប្រាក់បៀវត្សរ៍មន្ត្រីរាជការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងការកែលំអបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធនានាឱ្យទាន់សម័យឡើង ។ ចំណូលនេះក៏អាចប្រើប្រាស់សំរាប់ផ្តល់ការគាំទ្រខាងបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ឧស្សាហកម្មក្នុងស្រុកនិងសិប្បកម្ម ដែលនឹងជួយកាត់បន្ថយការពឹងផ្អែកលើទំនិញនាំចូល និងបង្កើតការងារបានច្រើនឱ្យប្រជាជនកម្ពុជាធ្វើ ។

សរុបមក ចំណូលពី O&G នឹងធ្វើឱ្យប្រទេសធូរធារឡើងបើសិនបំពេញបានលក្ខខណ្ឌមួយចំនួន ។ ចំណូលមិនមែនជាបណ្តាសាទេ ប៉ុន្តែបែបបទប្រើប្រាស់និងគ្រប់គ្រងវា អាចហុចផលជា "បណ្តាសា" រឺជា "ពរ" ។ វិទ្យាស្ថាន CDRI មានទស្សនវិស័យថា ចំណូលពី O&G នឹងគ្រប់គ្រងបានល្អ ហើយប្រើប្រាស់ប្រកបដោយឈ្លាសវៃ ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ ។

---

* អត្ថបទរៀបរៀងឡើងដោយ បណ្ឌិត សុខ ស៊ីណា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI នេះឆ្លុះបញ្ចាំងពីបទបង្ហាញរបស់ ឯ.ឧ. Joseph Mussomeli ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា និងលោក Douglas Gardner អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា នៅសន្និសីទចក្ខុវិស័យកម្ពុជា នៅថ្ងៃទី២២-២៣ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលរៀបចំដោយវិទ្យាស្ថាន CDRI ដោយរួមសហការជាមួយ ធនាគារអេអិនហ្សែតរ៉ូយ៉ាល់ ។

# ឱកាសជាប្រវត្តិសាស្ត្រដើម្បីសំរេចបានវិបុលភាពរួម និងធានាចីរភាពក្នុងរយៈពេលវែង

*បទបង្ហាញដោយលោក **Douglas Gardner** អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា*

*"កម្ពុជា ត្រូវតែរៀនពីប្រទេសដទៃទៀត ប្រើប្រាស់ចំណូលពីប្រេងកាតឱ្យមានប្រសិទ្ធភាព និងជៀសវាងបណ្តាសាពីប្រេងកាត" ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅវេទិកាសេដ្ឋកិច្ចកម្ពុជា នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ។*

ចំណូលយ៉ាងច្រើនពី O&G នៅបាតសមុទ្រកម្ពុជាដែលនឹងចាប់ផ្តើមបូមយកបានប្រហែលនៅឆ្នាំ២០១០ គឺជាឱកាសតែមួយពិត១សំរាប់ធានាកំណើនរយៈពេលវែងក្នុងប្រទេស ជួយកាត់បន្ថយភាពក្រីក្រឱ្យបានកាន់តែច្រើន បង្កើនសមធម៌ និងពង្រឹងស្ថិរភាពនៅប្រទេសកម្ពុជាដែលសំរេចបានដោយលំបាកកន្លងមក ។

## ឱកាសនេះល្អឯក ដោយសារហេតុផលច្រើនៈ

ហេតុផលទី១ គឺ O&G ភាគច្រើននៅបាតសមុទ្រ ពុំមានម្ចាស់ដីឯកជន រឺក្រុមម្ចាស់ដីណាមួយអាចទាមទារយកជាកម្មសិទ្ធិបានទេ ។ ដោយសារវាជាធនធានធម្មជាតិនៅបាតសមុទ្រកម្ពុជា វាពិតជារបស់ប្រជាជនកម្ពុជាគ្រប់១គ្នា ។

ហេតុផលទី២ គឺ O&G នៅបាតសមុទ្រ វាជាធនធានថ្មី និងគ្មានបញ្ហាលំបាកស្មុគស្មាញនៅក្នុងប្រវត្តិសាស្ត្រថ្មី១នេះទេ ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាមានសេរីភាព និងលទ្ធភាពអាចបត់បែនបានច្រើន ដើម្បីប្រើប្រាស់វាជួយលើកស្ទួយសុខមាលភាពរបស់ប្រជាជនភាគច្រើន ។

ហេតុផលទី៣ គឺតាមរយៈលទ្ធផលរកឃើញជាដំបូង១ ប្រេងកាតនិងឧស្ម័ន (O&G) នៅបាតសមុទ្រនេះ អាចផ្តល់ចំណូលហិរញ្ញវត្ថុយ៉ាងច្រើនដល់រដ្ឋាភិបាល ដែលគ្រប់គ្រាន់ដើម្បីបង្កើនគួរឱ្យកត់សំគាល់នូវការផ្តត់ផ្គង់សេវាសុខាភិបាល ការអប់រំ និងការថែទាំសុខភាពមានគុណភាព ពន្លឿនការរីកចំរើន ឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា (CMDGs) ជួយធានាកំណើនសេដ្ឋកិច្ចរយៈពេលវែង និងពង្រឹងស្ថិរភាពរយៈពេលវែងរបស់កម្ពុជា ។

## តើមានប្រេងច្រើនប៉ុណ្ណា?

បរិមាណប្រេងសំរាប់ធ្វើពាណិជ្ជកម្មមិនទាន់បញ្ជាក់ច្បាស់នៅឡើយទេ ប៉ុន្តែលទ្ធផលរកឃើញជាដំបូង១ មានសង្ឃឹមច្រើនណាស់ ។ បរិមាណប្រេងពាណិជ្ជកម្មនៅតំបន់ A កំពុងត្រូវបានវាយតំលៃដោយក្រុមហ៊ុន Chevron ។ តួលេខប៉ាន់ស្មានប្រាកដប្រជា ប្រហែលទទួលបាននៅពាក់កណ្តាលឆ្នាំនេះ ។ តួលេខដំបូង១បំផុត ដែលផ្សព្វផ្សាយនៅឆ្នាំមុន គឺមានប្រេងរហូតដល់ ៧០០លានធុង គ្រាន់តែនៅតំបន់ A មួយកន្លែងប៉ុណ្ណោះ ។

យោងតាមថ្លៃប្រេងនៅទីផ្សារអន្តរជាតិជាមធ្យម ៦០ដុល្លារ/ធុង បរិមាណប្រេងពាណិជ្ជកម្ម អាចផ្តល់ចំណូលសុទ្ធប្រចាំឆ្នាំដល់ថវិកាជាតិប្រហែល ១,៧ពាន់លានដុល្លារ[១] ។ ទឹកប្រាក់នេះតំណាងឱ្យបីដងនៃជំនួយអភិវឌ្ឍន៍ពីបរទេស (ODA) រឺជិតបីដងនៃចំណូលថវិកាចរន្ត និងលើសពី ៥០% នៃចំណូលបានពីការនាំចេញទំនិញ ។

ទោះបីគេធ្វើការសន្មតយ៉ាងប្រយ័ត្នប្រយែងថា អាចទទួលបានចំណូលតែពាក់កណ្តាលតួលេខខាងលើក្តី ក៏វានៅតែអាចផ្តល់ប្រហែល ០,៨៥ពាន់លានដុល្លារ ដល់ដំណើការថវិកាជាទូទៅរបស់រដ្ឋាភិបាលដែរ ។ វានឹងអាចរួមចំណែកធ្វើឱ្យចំណូលចំណាយថវិកាចរន្តកើនឡើងមួយជាពីរ ដោយធ្វើឱ្យចំណាយចរន្តខាងសុខាភិបាល និងអប់រំ អាចកើនជិតបួនដង ហើយនៅតែអាចបង្កើនគួរឱ្យកត់សំគាល់នូវខ្ទង់ចំណាយផ្សេង១ទៀត[២] ។

## ពរ រឺ បណ្តាសា?

ចំណូលពី O&G អាចជាឱកាសមួយដ៏ល្អបំផុតរបស់កម្ពុជាក៏ពិតមែន ប៉ុន្តែការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ច ឧបត្ថម្ភដោយ UNDP ក្នុងកិច្ចសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និងអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) នៅឆ្នាំ២០០៥-២០០៦ ក៏បានបង្ហាញដែរថា វាអាចជាការគំរាមកំហែងដ៏ធំបំផុតមួយដល់សុខមាលភាព និងស្ថិរភាពយូរអង្វែងនៅកម្ពុជា ។

ការសន្និដ្ឋានទាំងនេះ មានមូលដ្ឋានរឹងមាំយោងតាមបទពិសោធន៍ជាង ៤០ឆ្នាំកន្លងមក នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានចំណូលទាបជាច្រើន ។ ភាគច្រើននៃប្រទេសកំពុងអភិវឌ្ឍន៍សំបូរប្រេងកាត និងរ៉ែ (O&M) បានទទួលផលប៉ះពាល់អវិជ្ជមានពីកំណើនចំណូលបានពីធនធានទាំងនេះ ហើយប្រទេសខ្លះត្រូវរង្គោះរង្គើថែមទៀតផង[៣] ។

ជាទូទៅ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា អត្រាកំណើនរយៈពេលវែងនៃប្រទេសកំពុងអភិវឌ្ឍន៍ដែលសំបូរប្រេងកាត និងរ៉ែ មានកំរិត ៣០-៥០% ទាបជាងប្រទេស កំពុងអភិវឌ្ឍន៍ខ្សត់ប្រេងកាត និងរ៉ែ ។ម្យ៉ាងទៀត ប្រទេសសំបូររ៉ែធម្មជាតិ ក៏ចាញ់ប្រទេសខ្សត់រ៉ែដែរ ក្នុងវិស័យសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយជាច្រើន[៤] ។

## បទពិសោធន៍សាកលលោកស្តីពីបណ្តាសាធនធាន

ការពិនិត្យបទពិសោធន៍ក្នុង ៤០ឆ្នាំកន្លងមក នៅប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួលបណ្តាសាធនធាន បានបង្ហាញពីសញ្ញាប្រកាសអាសន្នមួយចំនួនដែលផុសឡើងនៅមុនពេលត្រូវរងគ្រោះធ្ងន់ធ្ងរដោយបណ្តាសា ។

សញ្ញានានាមានជាអាទិ៍ កំណើនយ៉ាងគំហុកនៃចំណូលរូបិយវត្ថុបរទេសបានមកពីការបូមយកធនធានធម្មជាតិមិនកកើតឡើងវិញ ព្រមទាំងៈ

- កង្វះតំលាភាពខាងហិរញ្ញវត្ថុ
- អភិបាលកិច្ចខាងហិរញ្ញវត្ថុអន់ខ្សោយ
- ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបាក់បែកជាដុំ១ និងមានចន្លោះប្រហោងច្រើន
- មូលដ្ឋានប្រមូលពន្ធតូចចង្អៀត និងអន់ខ្សោយ
- មានអំពើពុករលួយច្រើន និងលេចធ្លោ
- ជារដ្ឋកេងប្រវ័ញ្ច ដោយពួកមន្ត្រីព្យាយាមទាញយកប្រយោជន៍ផ្ទាល់ខ្លួន ឱ្យបានច្រើនបំផុត តាមរយៈការប្រើប្រាស់ដោយខុសឆ្គងនូវមុខតំណែងរដ្ឋ[៥]

- សមត្ថភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចទន់ខ្សោយ រហូតដល់ទៅមាន "ជំងឺហូឡង់"
- ការខ្ចីបុលច្រើនៗ ដោយអាងធនធានប្រេង ។

**ធាតុផ្សំនៃពរ**

ប្រទេសសំបូរប្រេងកាត ឧស្ម័ន ឬ រ៉ែ មួយភាគតូចដែលទទួលបានពរពីប្រេងកាត ក៏មានលក្ខណៈដូចគ្នាមួយចំនួនដែរ ដែលរួមមានការរំពឹងទុកពីកំណើនយ៉ាងតំហុកនៃប្រាក់ចំណូលបានពី ការប្រមូលយកធនធានធម្មជាតិដែលមិនកកើតឡើងវិញ ព្រមទាំង:

- ការរៀបចំផែនការទុកជាមុនសំរាប់ការគ្រប់គ្រង និងការធ្វើវិនិយោគដោយមានប្រសិទ្ធភាពនូវលំហូរហិរញ្ញវត្ថុដែលទទួលបាន
- មានតំលាភាពខ្ពស់
- មានការចូលរួមខ្លាំងក្លា និងសេចក្តីសំរេចសំខាន់ៗអំពីរដ្ឋសភា
- ស្ថាប័នសាធារណៈអភិវឌ្ឍន៍បានល្អ និងធ្វើការមានប្រសិទ្ធភាព
- អំពើពុករលួយមានកំរិតទាប និងមានប្រព័ន្ធច្បាប់ និងតុលាការដំណើរការល្អ
- សង្គមស៊ីវិលមានដំណើរការល្អ
- មានសមត្ថភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងសក្តិសិទ្ធិ
- មិនចូលចិត្តសន្សំបំណុល
- ការគ្រប់គ្រង និងវិនិយោគចំណូល អនុវត្តបានយ៉ាងសក្តិសិទ្ធិ ដើម្បីជំរុញការធ្វើចំរុះកម្មសេដ្ឋកិច្ច និងជៀសវាងការឡើងថ្លៃរូបិយវត្ថុក្នុងស្រុកហួសហេតុ
- អត្រាចំណាយធ្វើវិនិយោគ ដែលធានាបាននូវប្រសិទ្ធភាព និងសមធម៌នៅក្នុងកំរិតសមត្ថភាពរបស់រដ្ឋ និងសមត្ថភាពស្រូបយករបស់ប្រទេស (តាមធម្មតាត្រូវសំរួលដោយមូលនិធិធនធានធម្មជាតិមួយដែលមានតំលាភាព និងតាក់តែងបានល្អ)

**ចក្ខុវិស័យសំរាប់កម្ពុជា?**

ច្បាស់ហើយថា ពរប្រេងកាត មិនមែនទទួលបានជាស្វ័យប្រវត្តិទេ ។ ប៉ុន្តែសំណាងល្អដែរ បទពិសោធន៍នៅបរទេស អាចផ្តល់ជាការណែនាំដ៏មានតំលៃ ។

រាប់ថាជាសំណាងល្អដូចគ្នា រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បានផ្តល់មាត្រាដ៏សក្តិសិទ្ធិមួយ ដើម្បីអាចទទួលបានពរប្រេងកាត ។ រដ្ឋធម្មនុញ្ញណែនាំថារដ្ឋត្រូវធ្វើផែនការមួយច្បាស់លាស់សំរាប់គ្រប់គ្រងធនធាន ដូចជា O&G ហើយផែនការនោះ ត្រូវអនុម័តដោយប្រជាជន តាមរយៈសំលេងអ្នកតំណាងរបស់ពួកគេនៅក្នុងរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ ។

ការធ្វើផែនការទុកជាមុន និងការចូលរួមយ៉ាងច្រើនរបស់ប្រជាជននៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត គឺជាកត្តាដ៏សំខាន់ដែលពរប្រេងកាតបានកើតឡើង ចំពោះប្រទេសមានជោគជ័យល្អៗជាងគេ ក្នុងការនាំចេញប្រេងកាត ។

ម្យ៉ាងទៀតយោងតាមបរិបទស្ថាប័ន និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា បទពិសោធន៍អន្តរជាតិបានបង្ហាញពីគោលនយោបាយសំខាន់ៗ កិច្ចការពារផ្នែកច្បាប់និងស្ថាប័ន ដែលត្រូវដាក់អនុវត្តឱ្យបានយូរគួរសម មុនពេលចំណូលពីប្រេងកាតហូរចូលមក ដើម្បីធានាថា កម្ពុជាអាចជៀសផុតពីបណ្តាសា និងទទួលបានពរពិតៗ ។

**ការងារគោលនយោបាយ:** ត្រូវមាន ១) គោលនយោបាយច្បាស់លាស់ពីបែបបទគ្រប់គ្រងចំណូលពី O&G នាពេលអនាគត ២) គោលនយោបាយមានតំលាភាពពីរបៀបបែងចែកសម្បទាន O&G ដើម្បីឱ្យទូទាំងប្រទេសកម្ពុជា ទទួលបានអត្ថប្រយោជន៍ច្រើនបំផុត ៣) តំលាភាពលើប្រភេទ និងបរិមាណនៃការទូទាត់បង់ប្រាក់ និងលំហូរហិរញ្ញវត្ថុបានមកពីអាជ្ញាប័ណ្ណ O&G ការរុករក ការអភិវឌ្ឍន៍ និងការបូមយក និងជារួម គឺគោលនយោបាយច្បាស់លាស់ពីកំរិតតំលាភាពនៅក្នុងវិស័យនេះទាំងមូល ។

ប្រេងកាត និងឧស្ម័ននៅបាតសមុទ្រ គឺជាសម្បត្តិរបស់ប្រជាជនកម្ពុជាទាំងអស់គ្នា ដូច្នេះដាច់ខាតត្រូវមានការផ្តល់ព័ត៌មាន និងការបើកទូលាយនូវការជជែកវែកញែកជាសាធារណៈ ស្តីពីការប្រើប្រាស់ចំណូលពីប្រេងកាត និងឧស្ម័ន (O&G) នាពេលអនាគត ។ ដើម្បីឱ្យមានប្រសិទ្ធភាព និងអត្ថប្រយោជន៍ច្រើនបំផុតសំរាប់ប្រទេសទាំងមូល ការបែងចែកសម្បទានទៅឱ្យក្រុមហ៊ុនបរទេសគួរធ្វើឡើង តាមរយៈការដាក់ឱ្យដេញថ្លៃប្រកួតប្រជែងគ្នាជាការប្រសើរ ។

លក្ខខណ្ឌធំៗក្នុងកិច្ចសន្យាបែងចែកផលិតផល ដែលចែងពីរបៀបបែងចែកផលិតផល និងប្រភេទផ្សេងៗនៃលំហូរហិរញ្ញវត្ថុចូលមកកម្ពុជា គួរតែបើកទូលាយដល់សាធារណៈជនបានដឹង (ចេញជាសារព័ត៌មាន រឺដាក់នៅលើវេបសាយជាសាធារណៈ) ដើម្បីផ្តល់ព័ត៌មានអំពីការជជែកវែកញែកទានាជាសាធារណៈ ការរៀបចំផែនការពាក់ព័ន្ធ និងការធ្វើសេចក្តីសំរេចចិត្ត ។

**ការងារខាងច្បាប់:** ត្រូវមានច្បាប់ដ៏ល្អមួយស្តីពីប្រេងកាត សំរាប់គ្រប់គ្រងធនធាននេះ ដោយមានការបែងចែកសមហេតុផលនូវការទទួលខុសត្រូវនៅក្នុងការងាររដ្ឋ និង រវាងរដ្ឋនិងវិស័យមិនមែនរដ្ឋ ។ ត្រូវធានាផងដែរឱ្យច្បាប់មានសេចក្តីចែងច្បាស់លាស់ និងរលូនគ្នាល្អជាមួយនឹងច្បាប់ផ្សេងៗទៀត (ឧ. ច្បាប់ស្តីពីសារពើពន្ធ ច្បាប់បរិស្ថាន ...) ។

**ការងារខាងស្ថាប័ន:** នៅដំណាក់ការបច្ចុប្បន្ននៃការអភិវឌ្ឍន៍ស្ថាប័ននៅកម្ពុជា មានផលប្រយោជន៍ច្រើននឹងប្រើប្រាស់ថវិការដ្ឋ ដើម្បីកសាងមូលនិធិប្រេងកាតមួយ ដែលតាក់តែងបានល្អ និងមានតំលាភាព ដើម្បីធានាដល់ប្រសិទ្ធភាពនិងសមធម៌នៃចំណាយវិនិយោគ នៅក្នុងកំរិតមួយដែលកាត់បន្ថយជាអតិបរមានូវឱកាសដែលអាចកើតជំងឺហូឡង់ និងទទួលបណ្តាសាធនធានផ្សេងៗ ។

ដូចបានធ្វើហើយនៅប្រទេសមួយចំនួនដែលជៀសផុតពីបណ្តាសា លំហូរហិរញ្ញវត្ថុបានពី O&G អាចយកទៅដឹកលំដាប់ដំបូងនៅក្នុងមូលនិធិមួយដូចបញ្ជាក់ខាងលើ មុនពេលបើកផ្តល់តាមនីតិវិធីទៅឱ្យថវិកាជាតិ សំរាប់ធ្វើហិរញ្ញប្បទាន ទៅឱ្យគំរោងវិនិយោគដែលស្ថិតនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ។ ការបើកផ្តល់ត្រូវធ្វើតាមបរិមាណមួយដែលជំរុញឱ្យវិនិយោគមានប្រសិទ្ធភាពល្អ ក្នុងកំរិតសមត្ថភាពខាងស្ថាប័នដែលកំពុងអភិវឌ្ឍន៍ និងសមត្ថភាពស្រូបយករបស់ប្រទេស[១០] ។

ជាទូទៅ ការពង្រឹងថែមទៀតនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងជាកត្តាសំខាន់សំរាប់បញ្ចៀសបណ្តាសាធនធាន ។ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋាភិបាលកំពុងប្រឹងប្រែងបន្តទៅមុខ រឹរិតតែសំខាន់បំផុតទៀត នៅចំពោះមុខលទ្ធភាពមានកំណើនប្រាក់ចំណូលពី O&G យ៉ាងតំហុកចាប់ពីឆ្នាំ២០១០ តទៅ ។

ម្យ៉ាងទៀត ក៏មានតំរូវការធ្វើការបែងចែកឱ្យសមហេតុផលនៃទំនួលខុសត្រូវខាងស្ថាប័ន និងសមត្ថភាពពាក់ព័ន្ធនៅក្នុងវិស័យប្រេងកាត ។ សមត្ថភាពរបស់ CNPA ត្រូវពង្រឹងបន្ថែមក្នុងផ្នែកបច្ចេកទេសជាច្រើន និង

ត្រូវកំណត់ឱ្យកាន់តែច្បាស់ ពីការបែងចែកការទទួលខុសត្រូវជាមួយអង្គភាពរដ្ឋផ្សេងទៀត ។

## ការធ្វើវិនិយោគក្នុងវិបុលភាពរួម និងស្ថិរភាពរយៈពេលវែង: ការជំរុញ CMDGs

បញ្ហាមួយទៀតដែលកម្ពុជាកំពុងប្រឈម គឺការលៃចែកចំណាយអោយមានប្រសិទ្ធភាព តាមរយៈដំណើរការផ្ទេរថវិកា និង NSDP ដើម្បីកាត់បន្ថយឱ្យតិចបំផុតនូវគ្រោះថ្នាក់នៃបណ្តាសាធនធាន និងបង្កើនឱកាសទទួលបាន ពរឱ្យកើនខ្ពស់បំផុត ។ លទ្ធផលជាដំបូងៗនៃការស្រាវជ្រាវឧបត្ថម្ភដោយ UNDP ក្នុងកិច្ចសហការជាមួយ SNEC CNPA និងវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) បានជួយបំភ្លឺយ៉ាងច្រើន[១១] ។

ការរកឃើញទាំងនេះ ដែលបានមកពីការគណនាសាកល្បងបែបបរិមាណពីកំណើនសេដ្ឋកិច្ចកម្ពុជានៅក្រោមសេណារីយ៉ូ (O&G) ខុសៗគ្នា បង្ហាញថាវិធីសក្តិសិទ្ធិបំផុតដើម្បីកាត់បន្ថយឱកាសកើតជំងឺហូឡង់ និងបណ្តាសាធនធាន គឺត្រូវវិនិយោគមួយចំណែកធំនៃចំណូលពី O&G ទៅលើការអភិវឌ្ឍន៍ជនបទ ជាពិសេសការអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការកែលំអការអប់រំជាមូលដ្ឋាន ការបណ្តុះបណ្តាល និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ព្រមទាំង ហេដ្ឋារចនាសម្ព័ន្ធជនបទ ជាពិសេស អគ្គិសនី ផ្លូវ និងប្រព័ន្ធស្រោចស្រព ។ តំរូវការចាំបាច់ទាំងនេះ កើតឡើងដោយសារការប្រើប្រាស់មូលធនកំរិតទាបនៅតំបន់ជនបទភាគច្រើននាបច្ចុប្បន្ន ។ វិនិយោគលើធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធនៅជនបទបែបនេះ ក៏ប្រហែលជាអាចផ្តល់ដែនសកម្មភាពទូលាយជាងមុន សំរាប់ធ្វើចំរុះកម្មសេដ្ឋកិច្ច បង្កើតការងារនិងចំណូលនៅក្នុងវិស័យកសិកម្ម/ផលិតកម្ម និងរក្សាឱ្យមានកំណើនល្អក្នុងរយៈពេលវែង ។

ម៉្យាងទៀត ការគណនាសាកល្បងបែបបរិមាណ ក៏បង្ហាញផងដែរពីផលប៉ះពាល់វិជ្ជមានយ៉ាងច្រើនទៅលើសូចនាករសមធម៌ ហើយតាមរយៈនេះវាជួយជំរុញដល់ស្ថិរភាពសង្គមក្នុងរយៈពេលវែង ។

ផ្ទុយទៅវិញ ឱកាសកើតជំងឺហូឡង់ និងការបាត់បង់សមត្ថភាពប្រកួតប្រជែងក្នុងវិស័យកសិកម្ម/ផលិតកម្ម ប្រហែលនឹងកើតមានឡើង ដោយសារទៅអនាគត គឺមានភាគរយនៃចំណូលកាន់តែច្រើននឹងត្រូវបានទៅដល់តំបន់ទីក្រុង ។ ក្នុងសេណារីយ៉ូនេះ សូចនាករសមធម៌ប្រហែលជានឹងធ្លាក់ចុះយ៉ាងលឿន ដែលជាសញ្ញាមិនល្អសំរាប់ស្ថិរភាពសង្គម និងសុខមាលភាពប្រជាជន ។ សេណារីយ៉ូនេះ ក៏ច្រើនតែធ្វើឱ្យធ្ងន់ធ្ងរថែមទៀត នូវការប្រមូលផ្តុំដីធ្លីកំរិតខ្ពស់ និងវិសមភាពផ្សេងៗដែលជាប់ពាក់ព័ន្ធ ។

ការគណនាសាកល្បងពីដំបូងៗបង្ហាញថា ការធ្វើឱ្យមានតុល្យភាពប្រកបដោយសុវត្ថិភាពរវាងចំណាយប្រើប្រាស់ និងចំណាយវិនិយោគ មានសារៈសំខាន់បំផុត ។ ឥទ្ធិពលជំងឺហូឡង់ នឹងកើនឡើងយ៉ាងគំហុក នៅពេលមានភាគរយកាន់តែធំឡើងនៃចំណូលថ្មីៗ ត្រូវបានយកទៅប្រើក្នុងចំណាយប្រើប្រាស់ ។ វាមានផលប៉ះពាល់អវិជ្ជមានជាពិសេសទៅលើវិនិយោគ និងសមត្ថភាពប្រកួតប្រជែងរបស់វិស័យឯកជន ហើយការនាំចូលនឹងកើនដល់កំរិតគ្មានចីរភាព ។

យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និង NSDP បានសង្កត់ធ្ងន់លើការអភិវឌ្ឍន៍ជនបទ និងការសំរេចបាន CMDGs ។ ដោយសារ NSDP មិនបានគិតបញ្ចូលនូវលទ្ធភាពទទួលបានចំណូលដ៏ច្រើនពី O&G ដូច្នេះការទទួលចំណូលជាក់ស្តែង អាចធ្វើឱ្យសេណារីយ៉ូនៃ NSDP+ អាចជួយជំរុញកំណើននិងការកាត់បន្ថយភាពក្រីក្រនៅជនបទកាន់តែលឿន ព្រមទាំងការរីកចំរើនកាន់តែលឿនឈានទៅសំរេច CMDGs ដទៃទៀត ។

សរុបមក ការប្រើប្រាស់ចំណូលពី O&G ដើម្បីធ្វើវិនិយោគច្រើនៗទៅលើប្រជាជនជនបទ និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយគួបផ្សំនឹងកំណែទំរង់អភិបាលកិច្ច វាអាចជាវិធីដ៏សក្តិសិទ្ធិបំផុត សំរាប់បញ្ចៀសបណ្តាសាធនធាន ព្រមទាំងជួយធានាថា ចក្ខុវិស័យសំរាប់ប្រទេសកម្ពុជានិងប្រជាជន នឹងកាន់តែភ្លឺថ្លាឡើងនៅប៉ុន្មានទសវត្សរ៍ខាងមុខ ។

## កំណត់សំគាល់

១. ការគណនាផ្អែកលើថ្លៃប្រេងពិភពលោក ៦០ដុល្លារ/ធុង និងចំណាយលើការបូមយក ២០ដុល្លារ/ធុង ហើយ ៦០% នៃចំណូលដុល ត្រូវបានទៅរដ្ឋាភិបាល ដោយផ្អែកលើរូបមន្តក្នុងកិច្ចព្រមព្រៀងស្តីពីការបែងចែកផលិតផលជាមួយក្រុមហ៊ុន Chevron ។ រីឯតំបន់ B, C, D និង F វាអាចផ្តល់ចំណូលថែមទៀតនាពេលអនាគត ។

២. ប្រសិនបើយកតួលេខប៉ាន់ស្មានជាដំបូងៗនៃឧស្ម័នធម្មជាតិនៅតំបន់ A (ប្រហែលមាន 3-5 trillion cubic feet រឺ ១០០-១៥០ពាន់លានម៉ែត្រគូប) មកបូកបញ្ចូលផង ក្នុងមួយឆ្នាំៗរដ្ឋាភិបាលអាចបានចំណូលដល់ ៣៥០លានដុល្លារ តាមកិច្ចសន្យាបែងចែកផលិតផលជាមួយក្រុមហ៊ុន Chevron ជាបន្ថែមទៅលើលទ្ធផលហិរញ្ញវត្ថុដែលបញ្ជាក់នៅខាងលើនោះទៀត ។

៣. ពាក្យថា *បណ្តាសាធនធាន* ត្រូវបានកំណត់ថាជា "អភូតហេតុមួយដែលប្រទេសនាំមុខដោយវិស័យនាំចេញធនធានធម្មជាតិ បង្កើតបានចំណូលយ៉ាងច្រើនសំរាប់រដ្ឋាភិបាល តែបែរជានាំឱ្យសេដ្ឋកិច្ចមានភាពទ្រឹង និងពេលខ្លះឈានដល់អស្ថិរភាពខាងនយោបាយ" ។ បណ្តាសាធនធាន អាចមានធាតុផ្សំផ្សេងៗ រួមទាំងអត្រាប្តូរប្រាក់ពិតឡើងតំលៃខ្ពស់ពេក ហេតុនេះ ធ្វើឱ្យធ្លាក់ចុះសមត្ថភាពប្រកួតប្រជែងក្នុងវិស័យមិនមែនធនធានជាពិសេសវិស័យកសិកម្ម និងឧស្សាហកម្មផលិត និងបង្កជាការខ្ជះខ្ជាយ អំពើពុករលួយ/ការកេងប្រវ័ញ្ច និងកាត់បន្ថយគ្រឿងលើកទឹកចិត្តដល់ការបំពេញគណនេយ្យភាពរបស់អាជ្ញាធរចំពោះពលរដ្ឋ ។

៤. ឧទាហរណ៍គួរឱ្យចាប់អារម្មណ៍បំផុត គឺប្រទេសខ្សត់ O&M នៅអាស៊ីជាច្រើន ជាប្រទេសអ្នកមាន រីឯប្រទេសសំបូរ O&M ជាច្រើននៅអាមេរិកឡាទីន និងអាហ្វ្រិក ជាប្រទេសក្រីក្របំផុត និងជំពាក់បំណុលច្រើនជាងគេនៅលើពិភពលោក ។ ប្រទេសដែលល្បីល្បាញថាបានទទួលបណ្តាសាធនធាន មានជាអាទិ នីហ្សេរីយ៉ា អង់ហ្គោឡា លីបេរីយ៉ា, Sierra Leone, Equatorial Guinea, អេក្វាទ័រ វ៉េនេហ្ស៊ុយអេឡា ទ្រីនីដាតនិងតូបាហ្គោ (ថ្មីៗនេះ) Kazakhtan, former Zaire, ហ្វីលីពីននៅទសវត្សរ៍១៩៧០-៨០ និងប្រទេសជាច្រើនទៀត ។

៥. ឧទាហរណ៍លើកឡើងជាញឹកញាប់ទាក់ទងទៅនឹងចំណុចនេះ រួមមានរបបដឹកនាំពីមុនៗ នៅប្រទេសនីហ្សេរីយ៉ា លីបេរីយ៉ា Sierra Leone និង former Zaire ។

៦. "ជំងឺហូឡង់" គឺការឡើងថ្លៃពិតខ្ពស់ពេកនៃរូបិយវត្ថុជាតិ និងការបាត់បង់សមត្ថភាពប្រកួតប្រជែងនៅក្នុងវិស័យពាណិជ្ជកម្មមិនមែនប្រេងកាតជាពិសេស កសិកម្ម និងឧស្សាហកម្មផលិត ធ្វើឱ្យមូលដ្ឋានសកម្មភាពសេដ្ឋកិច្ចរួមតូច ភាពអត់ការងារធ្វើកើនឡើង និងចំណូលថយចុះ ។ ការថយចុះចំរុះកម្មសេដ្ឋកិច្ច និងកំណើនការពឹងផ្អែកលើវិស័យវត្ថុធាតុដើម

ធ្វើឱ្យប្រទេសងាយមានអស្ថិរភាពសេដ្ឋកិច្ច ដោយសារតែអស្ថិរភាពនៃទីផ្សារវត្ថុធាតុដើមជាក់លាក់ណាមួយដែលជាប់ទាក់ទិន ។

៧. ប្រទេសល្បីឈ្មោះជាងគេថាបានទទួលពរ គឺ ន័រវែស កាណាដា (Alberta) សហរដ្ឋអាមេរិក (Alaska) អូស្ត្រាលី ស៊ីលី និងបូស្វាណា ។ ប្រទេស Timor-Leste គេលើកឡើងជារឿយៗថា ជាប្រទេសកំពុងអភិវឌ្ឍន៍ដែលបានកសាងវិធីសាស្ត្រចាត់ចែងឧស្ម័ននៅបាតសមុទ្ររបស់ខ្លួន ដោយផ្អែកលើមេរៀនដែលប្រទេសផ្សេងៗរៀនសូត្របានក្នុង ៤០ឆ្នាំកន្លងទៅ ហើយអាចក្លាយជាគំរូសំរាប់ប្រទេសកម្ពុជា ។

៨. មាត្រា៥៩ នៃរដ្ឋធម្មនុញ្ញចែងថា រដ្ឋនឹងបង្កើតផែនការច្បាស់លាស់សំរាប់ការគ្រប់គ្រងធនធាន ដូចជា O&G ដើម្បីលើកស្ទួយសុខមាលភាព និងកិរិតជីវភាពរបស់ប្រជាជន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ហើយអំណាចទាំងនេះត្រូវបានប្រើប្រាស់តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ ។

៩. រាជរដ្ឋាភិបាលកម្ពុជា បានផ្ដួចផ្ដើមទំនាក់ទំនងការងារជាមួយកម្មវិធីតំលាភាពឧស្សាហកម្មយករ៉ែ (Extractive Industry Transparency Initiative: EITI) ដើម្បីជួយដល់ដំណើរការនេះ ។

១០.ឧទាហរណ៏: ទោះបីពីដំបូងគេយកពាក់កណ្ដាលនៃចំណូល ១,៧ពាន់លានដុល្លារ/ឆ្នាំ ដែលបានបញ្ជាក់ហើយ ទៅដំកល់ក្នុងមូលនិធិប្រេងកាតដែលរចនាតាក់តែងបានល្អនិងមានតំលាភាព (ដូចនៅប្រទេសសំបូរប្រេងមួយចំនួនដែលមានជោគជ័យ) គេនៅសល់ ០,៨៥ពាន់លានដុល្លារទៀតសំរាប់បើកផ្ដល់ទៅក្នុងថវិការដ្ឋ ។ រឿងនេះនឹងធ្វើឱ្យចំណូល និងចំណាយថវិកាចរន្តកើនឡើងមួយជាពីរ ហើយគេអាចចំណាយច្រើនជាងមុនជិត ៤ដងទៅលើវិស័យសុខាភិបាល និងអប់រំ ព្រមទាំងអាចបង្កើនខ្ទង់ចំណាយឯទៀតទាំងអស់ផង ។ ទន្ទឹមគ្នានេះ ទឹកប្រាក់ដំកល់នៅក្នុងមូលនិធិប្រេងកាត នឹងបន្តកើនឡើងដោយផ្ដល់ផលចំណេញតាមអត្រាទាញចំណូលអន្តរជាតិមួយយ៉ាងប្រសើរ ដែលអនុញ្ញាតឱ្យគេធ្វើការកែលំអនៅ ក្នុងវិស័យសុខាភិបាល និងអប់រំជាបន្តទៀត ហួសពីពេលដែលធនធានប្រេងកាតត្រូវបានបូមរលោះអស់ទៅ ដូច្នេះអាចធានាបាននូវស្ថិរភាព សេដ្ឋកិច្ច-សង្គមកិច្ច និងសុវត្ថិភាពខាងហិរញ្ញវត្ថុ ។

១១.យោងតាមតំរូវការរៀបចំផែនការឱ្យបានយូរពេលជាមុន និងត្រៀមជាស្រេចសំរាប់លទ្ធភាពច្រើនបែបយ៉ាង ការស្រាវជ្រាវនេះមានគោលដៅគណនាបរិមាណ និងបង្កើនផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ចសំរាប់កម្ពុជា ផ្អែកលើសេណារីយ៉ូមួយចំនួន ដោយប្រើគំរូលំនឹងទូទៅអាចគណនាបាននៃសេដ្ឋកិច្ច (Computable general equilibrium model of the economy) ។ សេចក្ដីព្រាងពីការរកឃើញក្នុងការស្រាវជ្រាវ នឹងចេញផ្សាយនៅប៉ុន្មានខែខាងមុខសំរាប់ការពិភាក្សា និងកែតំរូវ ។

# ជៀសវាងបណ្ដាសាធនធានៈ ការគ្រប់គ្រងឧស្សាហកម្មយករ៉ែនៅកម្ពុជា

*បទបង្ហាញរបស់ ឯ.ឧ. **Joseph A. Mussomeli** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា*

ឯកឧត្ដម អស់លោក លោកស្រី !

ខ្ញុំសូមអរគុណចំពោះការអនុញ្ញាតឱ្យខ្ញុំបានចូលរួមក្នុងក្រុមឧទ្ទេសនាមនេះ ។ កិច្ចប្រជុំស្ដីពីការគ្រប់គ្រងប្រេងកាត និងឧស្ម័នធម្មជាតិរបស់កម្ពុជា គឺពិតជាត្រូវចំពេលល្អណាស់ ។ ក្នុងរយៈពេល៣ឆ្នាំទៀត ឧស្សាហកម្មយករ៉ែនៅកម្ពុជា (ប្រេងកាត ឧស្ម័ន និងរ៉ែផ្សេងទៀត) អាចធ្វើឱ្យចំណូលប្រចាំឆ្នាំរបស់រដ្ឋកើនលើសពី មួយជាបី ទៅទៀត ។

ការសិក្សាមួយរបស់ UNDP បានបង្ហាញថា នៅថ្ងៃខាងមុខ ប្រាក់ចំណូលពីប្រេងកាតតែមួយមុខ អាចបានច្រើនជាងបីដងនៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលកម្ពុជាបានទទួលនៅឆ្នាំ២០០៥ ទៅទៀត ។

រឿងនេះគួរជាព័ត៌មានដ៏អស្ចារ្យហើយ ។ ជាការពិតណាស់ សំរាប់ប្រទេសក្រីក្រមួយចំនួន ឧស្សាហកម្មយករ៉ែ ជាអ្នកសង្គ្រោះសេដ្ឋកិច្ច ដោយជួយរំដោះប្រទេសចេញពីភាពក្រីក្រដែលហាក់ដូចជាទ័លច្រកទៅហើយ ហើយសំរាប់កម្ពុជា វាក៏អាចជាអ្នកសង្គ្រោះសេដ្ឋកិច្ចដែរ ។ ប៉ុន្តែអនាគតបែបនេះ នៅមិនទាន់ច្បាស់លាស់ទេ ។ តាមឆាកជីវិតរបស់យើងផ្ទាល់ យើងទាំងអស់គ្នាអាចដឹងថា ពរជាច្រើនដែលហាក់មើលឃើញទៅហើយ អាចប្រែក្លាយទៅជាបណ្ដាសាវិញ ។ នៅប្រទេសអាមេរិក គ្មានឆ្នាំណាមួយដែលគ្មានការចុះផ្សាយព័ត៌មាន ពីមនុស្សមួយចំនួនមានសំណាងល្អឈ្នះឆ្នោតបានរាប់លានដុល្លារ ប៉ុន្តែនៅទីបញ្ចប់បែរជាធ្លាក់ខ្លួនរឹតតែក្រ និងរឹតតែពិបាកចិត្តជាងកាលពីមុននោះទៀត ។ ភោគទ្រព្យមកដល់ភ្លាមៗ ក៏ពិបាកដោះស្រាយដូចសោកនាដកម្មភ្លាមៗដែរ ។ នៅប្រទេសជាច្រើន ភោគទ្រព្យបានពីការជីកយកធនធានគឺជាបណ្ដាសាគួរឱ្យតក់ស្លុត ដែលធ្វើឱ្យប្រជាជនកាន់តែក្រទៅៗ រីឯអ្នកមានអំណាចពុករលួយមួយចំនួនតូច បែរជាបូមយកចំណូល ដែលគួរយកទៅប្រើប្រាស់ដើម្បីលើកស្ទួយសុខមាលភាពរបស់ប្រជាជនទៅវិញ ។ ដល់យូរៗទៅ អំពើពុករលួយ និងកំណើនគំលាតរវាងអ្នកមាន និងអ្នកគ្មាន វានឹងបង្កដោយជៀសមិនផុតនូវចលាចលក្នុងសង្គម អស្ថិរភាពនយោបាយ និងទំនាស់ហិង្សា ។

តើកម្ពុជាត្រូវធ្វើអន្តរកាលយ៉ាងណា ដើម្បីឈានពីស្ថានភាពពឹងផ្អែកលើជំនួយទៅជាប្រទេសសំបូរធនធាន? តើកម្ពុជានឹងអាចបង្កើនភោគទ្រព្យ បានច្រើនជាអតិបរមា ហើយជំរុះចោលខ្នោះឃ្នាងខាងសង្គមកិច្ច នយោបាយ និងចិត្តសាស្ត្របន្សល់ពីរបបប៉ុលពតដែររឺទេ? តើកម្ពុជាអាចនឹងក្លាយជានាគអាស៊ីនៅសតវត្សរ៍ទី២១ដែររឺទេ ដោយអនុវត្តបាននូវរបៀបរបបអន្តរជាតិដ៏ប្រសើរបំផុត ក្នុងពេលដែលត្រូវបន្តដំណើរនៅលើមាគ៌ារបស់ខ្លួនផ្ទាល់ ដើម្បីឈានទៅរកការរីកចំរើនសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ? ចំពោះសំនួរទាំងនេះ ដើម្បីទទួលបានចំលើយ "វិជ្ជមាន" កម្ពុជាត្រូវការឆន្ទៈខាងនយោបាយជាងអ្វីៗទាំងអស់ ។ ឆន្ទៈល្អ ការធ្វើផែនការ និងការបណ្ដុះបណ្ដាល ទាំងអស់មិនអាចជួយឱ្យកម្ពុជាសំរេចបានអ្វីទេ ប្រសិនបើអ្នកដឹកនាំខ្វះឆន្ទៈនយោបាយ ដើម្បីទាមទារឱ្យគេយកប្រាក់ចំណូលបានពីឧស្សាហកម្មយករ៉ែ ទៅប្រើប្រាស់តែសំរាប់ធ្វើឱ្យប្រទេសជាតិបានល្អប្រសើរឡើង ។ ក្នុងសុន្ទរកថាដ៏ចំហ និងក្បោះក្បាយកាលពីថ្ងៃទី២២ កុម្ភៈ ២០០៧ សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានបង្ហាញពីបំណងចង់ឱ្យមានឆន្ទៈនយោបាយបែបនេះ ។ អ្នកត្រូវតែកសាងក្របខ័ណ្ឌគោលនយោបាយមានតំលាភាព និងបង្កើតរចនាសម្ព័ន្ធស្ថាប័នឱ្យបានសព្វគ្រប់ ដើម្បីទប់ស្កាត់ការប្រើប្រាស់ប្រាក់ចំណូលមិនបានត្រឹមត្រូវពីសំណាក់ជនណាមួយ ទោះមានអំណាចប៉ុណ្ណាក៏ដោយ ។

មុននឹងផ្ដល់អនុសាសន៍ខាងគោលនយោបាយដ៏ជាក់លាក់ ខ្ញុំសូមគូស

វិលេចពីគ្រោះថ្នាក់នៃបណ្ដាសាធនធានដែលប្រទេសជាច្រើនបានជួបប្រទះ ។ ផ្ទុយពីការរំពឹងទុក ការរកឃើញធនធានធម្មជាតិដ៏ស្ដុកស្ដម្ភ មិនមែនសុទ្ធតែនាំឱ្យមានកំណើនសេដ្ឋកិច្ច/សង្គមកិច្ចនោះទេ ហើយនៅប្រទេសមួយចំនួន ប្រជាជនជាទូទៅរឹតតែក្រថែមទៀត បន្ទាប់ពីទទួលបានចំណូលពីប្រេងកាតអស់រយៈ៣០ឆ្នាំមក ។ បណ្ដាសាចាប់ផ្ដើមឡើងនៅពេលដែល "អ្នកតថ្លៃ" របស់រដ្ឋាភិបាល មិនទទួលបានថ្លៃខ្ពស់ពី ធនធានធម្មជាតិដែលមិនកកើតឡើងវិញ។ អ្នកទាំងនោះ តាមធម្មតាច្រើនប្រើប្រាស់ដំណើរការគ្មានតំលាភាពដែលផ្ដោតលើភោគទ្រព្យក្នុងរយៈពេលខ្លី ជាជាងការអភិវឌ្ឍន៍ជាតិ នៅក្នុងរយៈពេលវែង ។ ពួកគេច្រើនតែមានការយល់ដឹងខាងបច្ចេកទេសតិចតួចពីភាពស្មុគស្មាញនៃអាជីវកម្ម និងរបៀបរបបនៅក្នុងឧស្សាហកម្មយករ៉ែ ។

ជួនកាល រដ្ឋាភិបាលមិនបានធ្វើផែនការសំរាប់ចំណូលយ៉ាងគំហុតចៀសមិនរួចពាក់ព័ន្ធនឹងការឡើងចុះថ្លៃប្រេង ឧស្ម័ន និងរ៉ែផ្សេងៗ លើពិភពលោកទេ ។ ជារឿយៗ រដ្ឋាភិបាលនៅតែពឹងផ្អែកលើស្ថាប័នហិរញ្ញវត្ថុដែលផ្ដល់កំចីសំរាប់រ៉ាប់រងកង្វះថវិកា ហើយអាចឈានដល់ការជំពាក់បំណុលច្រើនហួសហេតុ និងអតិផរណាខ្ពស់ពេក ។

ចំណុចធ្ងន់ធ្ងរបំផុតគឺ ប្រទេសមួយចំនួនបានធ្វើការសំរេចចិត្តសាមញ្ញពេកក្នុងការប្រើប្រាស់អតិរេកធនធាន ដើម្បីបន្ធូរវិន័យខាងសារពើពន្ធ ។ គឺដូចជាកុមារដែលមិនធ្លាប់គិតអ្វីសោះពី ផលវិបាករយៈពេលវែងនៃជំរើសរបស់ខ្លួន ប្រទេសទាំងនោះធ្វើហាក់ដូចជាប្រាក់ចំណូលមិនចេះរីងស្ងួតសោះ ហើយពួកគេមិនចាំបាច់ធ្វើសកម្មភាពប្រកបដោយទំនួលខុសត្រូវឡើយ ។ នៅទីបំផុតសេដ្ឋកិច្ចក៏វិលវល់ធ្លាក់ចុះ ដោយសារកំណើនចំណាយប្រើប្រាស់សាធារណៈវាខ្លាំងជាងការបង្កើនចំណាយជួយផលិតកម្មក្នុងស្រុក ហើយក៏បង្កអតិផរណាក្នុងស្រុក និងការខូចខាតដល់វិស័យផលិតកម្មក្នុងសេដ្ឋកិច្ច ។

តើរឿងនេះមានអត្ថន័យយ៉ាងដូចម្ដេច ចំពោះស្ថានភាពនៅកម្ពុជា? អតិផរណាអាចនាំឱ្យចំណាយអស់កាន់តែច្រើន ដើម្បីផលិតបានផលកសិកម្ម និងផលិតផលផ្សេងទៀតនៅកម្ពុជា ដូច្នេះត្រូវថយចុះកំលាំងប្រកួតប្រជែង នៅក្នុងទីផ្សារពិភពលោក ។ សរុបមក ប្រសិនបើប្រាក់ចំណូលបានពីឧស្សាហកម្មយករ៉ែគ្មានការគ្រប់គ្រងសមស្របទេ ឧស្សាហកម្មកាត់ដេរកម្ពុជា ដែលប្រើកម្មករ ៣៣៤.០០០នាក់ និងទទួលប្រាក់ឈ្នួល ២៩២លានដុល្លារ/ឆ្នាំ ហើយនាំចេញបាន ២,៦ពាន់លានដុល្លារនៅឆ្នាំ២០០៦ នឹងត្រូវខូចខាត ហើយទីបំផុតនឹងដួលរលំ ។ នេះជាសេណារីយ៉ូមិនល្អមួយដែលអាចចៀសវាងបាន ។ នៅមានជាច្រើននាក់ក្នុងជួររដ្ឋាភិបាលកម្ពុជាដែលបានទទួលស្គាល់ និងកំពុងធ្វើការងារ ដើម្បីគ្រប់គ្រងដោយមានទំនួលខុសត្រូវខ្ពស់នូវឧស្សាហកម្មរ៉ែនៅប្រទេសកម្ពុជាយើង ។

សហគមន៍ពិភពលោក បានទទួលបទពិសោធន៍ល្អៗជាច្រើននៅប៉ុន្មានទសវត្សរ៍ចុងក្រោយ ពីរបៀបគ្រប់គ្រងហានិភ័យ និងទទួលបានរង្វាន់ល្អពីការអភិវឌ្ឍន៍ប្រេង ឧស្ម័ន និងរ៉ែផ្សេងទៀត ។ កម្ពុជាក៏មានឱកាសរៀនសូត្រពីបរាជ័យរបស់ប្រទេសខ្លះ និងពង្រីកបទពិសោធន៍មានជោគជ័យរបស់ប្រទេសឯទៀត ។

## **យើងសូមផ្ដល់អនុសាសន៍ខាងគោលនយោបាយដូចតទៅសំរាប់ជាការពិចារណា:**

១) យើងអបអរសាទររដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់លើកម្មវិធីតំលាភាពឧស្សាហកម្មយករ៉ែ (EITI) ហើយសង្ឃឹមថា ក្នុងពេលឆាប់ៗ កម្ពុជានឹងក្លាយជាប្រទេសអនុវត្តកម្មវិធីនេះ ។ នេះជាជំហានគួរឱ្យត្រេកអរមួយដែលបង្ហាញពីការតាំងចិត្តរបស់រដ្ឋាភិបាល ដើម្បីបង្កើតតំលាភាពក្នុងប្រព័ន្ធចុះកិច្ចសន្យាខាងឧស្សាហកម្មយករ៉ែ ។

២) រដ្ឋាភិបាលគួរកែលំអច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងការផ្ដល់ព័ត៌មាន និងការត្រួតពិនិត្យលើប្រាក់ចំណូលជាតិ ដើម្បីធានាឱ្យប្រាក់ចំណូលពីឧស្សាហកម្មរ៉ែ មានការតាមដានមើល និងបែងចែកជាចំហ សំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

៣) រាជរដ្ឋាភិបាលកម្ពុជាគួរពិនិត្យឡើងវិញ ពីគោលនយោបាយគ្រប់គ្រងប្រាក់ចំណូល ។ គោលនយោបាយទាំងនោះ គួរឆ្លើយតបនឹងសំនួរសំខាន់ៗដូចជា "ត្រូវចំណាយអ្វី" "ត្រូវសន្សំអ្វី" និង "នៅពេលណា" ។ តើចំណូលត្រូវហូរចូលរតនាគារតាមវិធានអ្វី? តើកម្ពុជានឹងដើរតាមគំរូរបស់បណ្ដាប្រទេសខាងជើង (Nordic countries) និងបង្កើតមូលនិធិប្រាក់សន្សំសំរាប់អ្នកជំនាន់ក្រោយរឺទេ? បើសិនធ្វើដូច្នេះ តើត្រូវបែងចែកប្រាក់ចំណូលប៉ុន្មានភាគរយទៅដោះស្រាយការចំណាយប្រចាំឆ្នាំ ដើម្បីជួយទ្រទ្រង់ប្រព័ន្ធអប់រំ ការថែទាំសុខភាព ហេដ្ឋារចនាសម្ព័ន្ធជនបទ កិច្ចការពារព្រៃត្រូពិច និងការអភិវឌ្ឍន៍ជាអាទិភាពផ្សេងទៀត?

៤) ការងាររដ្ឋាភិបាលដើម្បីកសាងច្បាប់ថ្មីស្ដីពីប្រេងកាត គួរតែពន្លឿនឡើង ដើម្បីធានាឱ្យមានក្របខ័ណ្ឌច្បាប់មានប្រសិទ្ធភាព និងតំលាភាពល្អ ។

៥) សេចក្ដីព្រាងវិសោធនកម្មសំរាប់ច្បាប់ស្ដីពីសារពើពន្ធ ដែលមានចែងនូវបទប្បញ្ញត្តិយ៉ាងច្បាស់លាស់និងមានប្រសិទ្ធភាពស្ដីពី ការយកពន្ធលើឧស្សាហកម្មប្រេងកាត គួរតែមានការអនុមតិ និងបញ្ជូនទៅសភាជាតិ ។ ដើម្បីអនុវត្តប្រព័ន្ធពន្ធដារកែសំរួលឡើងវិញនេះ នាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវតែពង្រឹងបន្ថែម និងត្រូវមានអ្នកជំនាញឯកទេសខាងគ្រប់គ្រងពន្ធ លើឧស្សាហកម្មយករ៉ែ ។

៦) សភាជាតិគួរចាត់វិធានការជាបន្ទាន់ ដើម្បីបង្កើនសមត្ថភាពខ្លួនក្នុងការបំពេញតួនាទីពិនិត្យតាមដាន ដូចជា ការបង្កើតគណៈកម្មការអចិន្ត្រៃយ៍មួយដែលមានតួនាទីជាក់លាក់ ក្នុងការពិនិត្យតាមដានលំហូរចំណូលមកពីឧស្សាហកម្មយករ៉ែ ។

៧) រដ្ឋាភិបាលគួរពន្លឿនការអនុមតិច្បាប់ស្ដីពីសេរីភាពក្នុងការទទួលបានព័ត៌មាន ដែលនឹងចងក្រងជាច្បាប់ នូវគោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋានតំរូវឱ្យរដ្ឋាភិបាលធ្វើការងាររបស់ខ្លួនតាម បែបបទមានតំលាភាពនិងបើកចំហ ដើម្បីឱ្យអ្នកដឹកនាំមានគណនេយ្យភាពលើការសំរេចចិត្ត និងសកម្មភាពរបស់ខ្លួន ។ ម្យ៉ាងទៀត រដ្ឋាភិបាលគួរអនុម័តនិងអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងបង្កើតស្ថាប័នឯករាជ្យមួយ ដែលអាចស៊ើបអង្កេតពីអំពើពុករលួយផ្សេងៗ នៅតាមស្ថាប័នរដ្ឋាភិបាល ។

ជាទីបញ្ចប់ បន្ទាប់ពីបានរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល១ឆ្នាំកន្លះមក ខ្ញុំបានពិនិត្យឃើញថា មានរឿងតិចតួចណាស់ដែលប្រជាជនកម្ពុជាឯកភាពតាមទាំងអស់គ្នា ។ ប៉ុន្តែមានរឿងពីរដែលពួកគេយល់ឃើញដូចគ្នាទាំងអស់ ដោយមិនគិតពីអាយុ គណបក្សនយោបាយ និងស្ថានភាពសេដ្ឋកិច្ចឡើយ ។ ទី១ ពួកគេលើកឡើងដោយមានមោទនភាព ពីអារ្យធម៌ខ្មែរដ៏រុងរឿង ដែលបានរីកស្គុះស្គាយកាលពីច្រើនសតវត្សរ៍មុន ។ ទី២ ពួកគេទាំងអស់តែងរំលឹកឡើងដោយអារម្មណ៍ពុះពោរថា កាលពី៥០ឆ្នាំមុន កម្ពុជាគឺជាគំរូដែលគេចង់បានគ្រប់គ្នានៅអាស៊ីអគ្នេយ៍ ជាប្រទេសដែលប្រជាជនមានការអប់រំខ្ពស់ មានសេវាថែទាំសុខភាពល្អ និងមានបរិយាកាសវប្បធម៌ដ៏រស់រវើក និងបើកទូលាយ ជាងប្រទេសនៅជិតខាងទាំងអស់ ។

តទៅទំព័រទី ២២